# កិច្ចច្រត់ព្រះនង្គ័លនៅតំបន់ប្រាសាទសំបូរព្រៃគុក

តាមទំនៀមទម្លាប់ខ្មែរតាំងពីបុរាណកាលមក នៅដើមដំបូងនៃការបើករដូវធ្វើស្រែចំការ តែងតែមានប្រារព្ធពិធីមួយជាទៀងទាត់ដែលគេស្គាល់ថា "ច្រត់ព្រះនង្គ័ល"។ ភាគច្រើន មនុស្សម្នាតែងស្គាល់ព្រះរាជពិធីច្រត់ព្រះនង្គ័លដែលរៀបចំឡើងជាថ្នាក់ជាតិ ប្រារព្ធនៅវាលមេរុ ក្បែរព្រះបរមរាជវាំង ក្នុងរាជធានីភ្នំពេញ និងនៅតាមបណ្ដាខេត្តផ្សេងៗ។ ដោយឡែក យ៉ាងហោចណាស់មានភូមិចំនួនពីរនៅតំបន់ប្រាសាទសំបូរព្រៃគុក ដែលនៅរក្សាប្រពៃណីច្រត់ព្រះនង្គ័លបានមកដល់សព្វថ្ងៃ គឺភូមិសំបូរ (ស្រុកប្រាសាទសំបូរ) និងភូមិចំណាស់ចាស់ (ស្រុកប្រាសាទបល្ល័ង្ក)។ លំដាប់នៃកិច្ចពិធីច្រត់ព្រះនង្គ័លភូមិទាំងពីរ មានលក្ខណៈខុសគ្នាខ្លះ ប៉ុន្តែមានអត្ថន័យរួមគ្នាមួយ គឺ ការសុំពរជ័យមង្គលពីអ្នកតាចាស់ស្រុក ដើម្បីបើករដូវធ្វើស្រែចម្ការឱ្យមានទឹកភ្លៀងគ្រប់គ្រាន់ និងសុំសេចក្ដីសុខសប្បាយ ចៀសឆ្ងាយពីរន្ទះបាញ់នៅរដូវវស្សា។ តើកិច្ចច្រត់ព្រះនង្គ័លនៅភូមិទាំងពីរមានលំដាប់លំដោយយ៉ាងណាខ្លះ?

នៅក្នុងភូមិសំបូរ គេតែងប្រារព្ធពិធីនេះឡើងនៅក្នុងពិសាខ ដែលកាលបរិច្ឆេទច្រើនតែប្រហាក់ប្រហែលនឹងព្រះរាជពិធីច្រត់ព្រះនង្គ័លរបស់ថ្នាក់ជាតិ។ ប៉ុន្តែ អ្នកស្រុកមានត្រណមមួយ គឺត្រូវតែរើសឱ្យចំថ្ងៃអង្គារ និងថ្ងៃសៅរ៍។ គេពន្យល់ថា ថ្ងៃអង្គារ គឺជាថ្ងៃរឹងដែលពពួកអមនុស្សមានសិទ្ធិចេញក្រៅ រីឯថ្ងៃសៅរ៍ពេលរសៀលគឺជាថ្ងៃដែលពពួកអមនុស្សអាចទទួលសំណែនរបស់មនុស្សបានពេញលេញ។ កិច្ចនេះ គេប្រារព្ធឡើងនៅទីតាំងខ្ទមអ្នកតាចាស់ស្រុក (អ្នកតាទ្វារ) នៅត្រង់កណ្ដាលភូមិ ហើយគេបន្តទៅដល់ទីតាំងដីស្រែនានា។ នៅក្នុងកិច្ចនោះ អ្នកស្រុកបានយកលាជដែលមានគ្រាប់ធំៗពត់ចេញជារាងវង្វង់ដោយនៅលើនំនាឡិមកពីផ្ទះរៀងៗខ្លួន ដោយគេសន្មតថា នំនាឡិប្រៀបដូចជាដីដែលកំពុងដាំដុះដំណាំស្រូវ ហើយដាក់វាចូលទៅក្នុងកញ្ច្រែងឬល្អី ឲ្យឈ្មោះថា «ព្រលឹងស្រូវ»។ ជាងនេះទៅទៀត អ្នកចូលរួមក៏បានយកដើមសណ្ដែកព្រៃមកកាន់កន្លែងប្រារព្ធពិធីផង ដោយសន្មតដើមនោះជា "ដើមព្រះភូមិ" ហើយក៏ជានិមិត្តរូបនៃព្រលឹងស្រូវផង។ ព្រលឹងស្រូវដែលគេកាន់មកពីផ្ទះ គឺគេយកទៅតម្រៀបនៅក្នុងខ្ទមអ្នកតា ហើយដើមសណ្ដែកព្រៃគេយកទៅដោតនៅតាមសសររោងអ្នកតា ឬដើមឈើនៅកន្លែងប្រារព្ធពិធីនោះ។ យើងសង្កេតឃើញថា គ្រឿងរណ្ដាប់ដែលមាននៅពេលនោះ គឺមិនខុសគ្នាពីការឡើងអ្នកតាចាស់ស្រុកឡើយ ឧទាហរណ៍ មាន់ស្ងោរ ពៃ សង្សឹក (ដាក់របស់របរបញ្ជូន) ។ល។ ជាកិច្ចចាប់ផ្ដើម ជម្នឿងជាអ្នករៀបចំកិច្ចនេះ ចាប់ផ្ដើមរៀបចំពិធីសែនព្រេនដល់អ្នកតាចាស់ស្រុក ដោយអញ្ជើញក្រុម

អត្ថបទដោយ៖ ម៉ង់ រ៉ាលី

អមនុស្សមកសេពសោយសំណែនដែលគេបានរៀបចំ។ ពេលសែនព្រេនរួចរាល់ ពិធីបញ្ជូនក៏ចាប់ផ្ដើមឡើង ដែលភាគច្រើនអ្នកកាន់មាន់ក្ដាំងជាមនុស្សចាស់ ពៃនិងសង្ឃឹកជាកូនក្មេង ហើយអ្នកចូលរួមផ្សេងទៀតកាន់ព្រលឹងស្រូវនិងដើមព្រះភូមិមកជាមួយផង ហើយដង្ហែទៅទិសខាងត្បូង។ គេជឿថា ទិសខាងត្បូង គឺជាទិសពិសេសមួយដែលអាចនាំឧបទ្រព្យចង្រៃចេញពីភូមិ ព្រោះខ្យល់នៅតំបន់នោះបក់ពីជើងទៅត្បូង។ នៅពេលនោះ អ្នកចូលរួមបានយកដើមព្រះភូមិមួយដើមរបស់ខ្លួនទៅដោតនៅតាមដីស្រែរៀងៗខ្លួន ដោយគេត្រណមថា ពេលដើរទៅដោតមិនត្រូវងាកក្រោយ ហើយដោតដើមព្រះភូមិឱ្យចំមុខផ្លូវទឹកដែលហូរចូលស្រែ ឬយ៉ាងហោចណាស់ត្រូវដោតឱ្យចំពាក់កណ្ដាលស្រែ។ ការដោតនៅមុខផ្លូវទឹកដែលហូរចូលស្រែនេះ ក្នុងជំនឿថា បន្ទាប់ពីបានសែនព្រេនដល់អ្នកតារួចមក នឹងមានទឹកបរិបូណ៌សម្រាប់បង្កបង្កើនផលស្រូវ។ រីឯ ដើមព្រះភូមិផ្សេងទៀតដែលនៅសល់ ត្រូវចងផ្ដួបគ្នាជាមួយព្រលឹងស្រូវ ហើយយកវាទៅដោតនៅក្នុងច្រមនៅតាមសសរកន្ទោងផ្ទះរៀងៗខ្លួន។

កិច្ចនេះនៅមិនទាន់ចប់សព្វគ្រប់នៅឡើយទេ ពោល គឺអ្នកស្រុកទាំងក្មេង ទាំងចាស់ត្រូវអង្គុយប្រមូលផ្ដុំគ្នានៅវាលស្រែខាងត្បូងភូមិដដែល ដើម្បីរង់ចាំរំអិលថ្មដែលគេយកមកពីប្រាសាទសំបូរព្រៃគុក។ នៅអំឡុងពេលដែលគេកំពុងប្រារព្ធពិធីនៅអ្នកតាទ្វារ (ត្រង់កណ្ដាលភូមិ) នៅខ្ទមអ្នកតាចាស់ស្រុកនៅសំបូរព្រៃគុកឯណោះ មានកិច្ចមួយទៀតដែលគេហៅថា "កិច្ចដុសរំអិលថ្ម"។ ការដុសយករំអិលថ្មនេះ ធ្វើឡើងដោយមនុស្សប្រុសមួយក្រុមនៅខាងមុខជណ្ដើរបុរាណក្នុងក្រុមប្រាសាទសំបូរ (ក្រុមខាងជើង)។ កិច្ចដុសរំអិលថ្មនេះទំនងកើតមានឡើងរាប់សតវត្សរ៍មកហើយ ទើបបានជាជណ្ដើរជាច្រើននៅក្រុមប្រាសាទសំបូរ ក្លាយទៅជាក្រហូងធំៗអស់ទៅហើយ។ ការដុសរំអិលថ្ម គេត្រូវយកទឹកមកស្រោចនៅលើផ្ទាំងថ្មជណ្ដើរបុរាណរបស់ប្រាសាទ ហើយយកឥដ្ឋមកដុសបង្កើតបានជា រំអិល ឬកំអែលថ្ម ដែលមានពណ៌ទឹកក្រូចដូចពណ៌របស់ឥដ្ឋដែរ។ បុរសមួយក្រុមដែលជាអ្នកដុសរំអិលថ្ម ក៏មានត្រណមដូចគ្នា គឺមិនត្រូវនិយាយរកនរណាឡើយកំឡុងពេលដែលគេកំពុងដុស។ ពេលដុសបានហើយ គេយករំអិល ឬកំអែលថ្មនោះ មកដាក់នៅលើស្លឹករុក្ខជាតិមួយប្រភេទឈ្មោះថា "ប្រទាលអោបជុំ" (អ្នកស្រុកហៅជាគ្រៀមភាសាថា "អាជុំ")។ បន្ទាប់មក ពិធីដង្ហែរំអិលថ្មពីខ្ទមអ្នកតាចាស់ស្រុកឆ្ពោះទៅកាន់ទីស្រែដែលមនុស្សកំពុងរង់ចាំក៏ចាប់ផ្ដើមឡើង។ ពេលទៅដល់ទីស្រែ បុរសម្នាក់ដែលគេស្គាល់ថាជាជម្មើង (អ្នករៀបចំកិច្ច) បានតំណាងឱ្យអ្នកភូមិដែលចាំទទួលរំអិលថ្មបានសួរឆ្លើយឆ្លងគ្នាទៅក្រុមបុរសកាន់រំអិលថ្ម។ ពេលនោះ ការដណ្ដើមរំអិលថ្មក៏ចាប់ផ្ដើមឡើង មានទាំងមនុស្សចាស់ និងកូនក្មេង។ មនុស្សចាស់ បាន

អត្ថបទដោយៈ ម៉ង់ វ៉ាលី

យករំអិល ឬកំអែលថ្មនោះទៅចឹមនៅលើថ្ងាសក្មេងៗ ដែលគេជឿថា ការចឹមនៅលើថ្ងាសក្មេងៗនេះ ដើម្បីសុំសេចក្តីសុខសប្បាយ ចៀសផុតពីរន្ទះបាញ់ ដ្បិតនៅរដូវវស្សាក្មេងៗនៅក្នុងភូមិនេះ ហើយដែលតែងទៅឃ្វាលគោប្រឈមនឹងរន្ទះបាញ់ជាងចាស់ៗ។ ដូច្នេះហើយទើបបានជាគេឃើញបង្គោលឈើនៅជុំវិញខ្ទមអ្នកតាទ្វារមានបន្ទះដែកស្រោបព័ទ្ធជុំវិញតាមជំនឿរបស់ខ្មែរក្នុងការពាររន្ទះ។ ការដាក់បន្ទះដែកស្រោបជុំវិញបែបនេះ ក៏គេឃើញមាននៅតាមកំពូលប្រាសាទបុរាណរបស់ខ្មែរដែរ តួយ៉ាងនៅប្រាសាទភ្នំត្រប់ ខេត្តកំពង់ចាម ជាដើម។ កិច្ចដុសរំអិលថ្មនេះហាក់ដូចមានន័យស្រដៀងនឹងរឿងព្រះគ្រឹស្ណដែរ ត្រង់ឈុតព្រះគ្រឹស្ណទ្រភ្នំបាំងភ្លៀងផ្គររន្ទះរបស់ព្រះឥន្ទ្រការពារក្មេងៗគង្វាលគោ ព្រោះការលាបរំអិលថ្មក៏បំណងគេចពីរន្ទះរបស់ព្រះឥន្ទ្រដូចគ្នា។ កិច្ចដុសរំអិលថ្ម និងកិច្ចប្រុត់ព្រះនង្គ័លដែលរៀបរាប់ខាងលើ ហាក់ដូចជាកិច្ចពីរផ្សេងគ្នា តែមានន័យរួមមួយ គឺការរីកចម្រើនដុះដាលនៃភោគផល គ្រាន់តែមួយជាស្រូវ និងមួយទៀតជាមនុស្ស។

ចំណែកឯនៅភូមិចំណារចាស់វិញ គេប្រារព្ធឡើងជារៀងរាល់ឆ្នាំនៅខ្ទមអ្នកតាចាស់ស្រុកក្នុងភូមិ ហើយក៏ជ្រើសរើសយកថ្ងៃអង្គារ ឬថ្ងៃសៅរ៍ដូចគ្នាដែរ។ ក្នុងពិធីនោះ អ្នកស្រុកបានធ្វើព្រលឹងស្រូវដែលធ្វើពីលាជដោតនៅលើនំនាឡិដូចនៅភូមិសំបូរដែរ ប៉ុន្តែអ្នកចូលរួមមិនមានយកដើមសណ្តែកព្រៃ (ដើមព្រះភូមិ) មកជាមួយដូចភូមិសំបូរទេ។ ផ្ទុយទៅវិញ គេបានយកពូជស្រូវរបស់ខ្លួនមកពីផ្ទះមកកាន់ទីកន្លែងប្រារព្ធពិធី។ ជាងនេះទៅទៀត អ្វីដែលគួរកត់សម្គាល់ខ្លាំងនោះគឺ អ្នកចូលរួមត្រូវយកក្រមា និងមួកមកក្រាលនៅខាងមុខខ្ទមអ្នកតា។ នៅក្នុងកិច្ចនោះ ក្រមា គឺតំណាងឱ្យដីស្រែ ហើយមួកតំណាងឱ្យទឹក។ ព្រលឹងស្រូវ គឺតម្រៀបនៅក្នុងខ្ទមអ្នកតាដូចនៅភូមិសំបូរដែរ រីឯគ្រាប់ពូជស្រូវត្រូវចាក់ចូលចាន ឬកញ្ជើជុំរួមគ្នាមួយ។ អ្នកភូមិមានជំនឿថា អ្នកតាដែលការពារដីស្រែចំការនៅក្នុងសហគមន៍របស់ពួកគេមានឈ្មោះថា "យាយរដ្ឋ" និង "តាកែវ"។ យាយរដ្ឋ ជាអមនុស្សស្រីនៅក្នុងសហគមន៍នេះពាក់សង្វារឈៀង។ ដូច្នេះហើយ រូបស្នងរបស់យាយរដ្ឋ ក៏ត្រូវមានពាក់សង្វារឈៀងដូចគ្នាដែរ។ បន្ទាប់ពីបានធ្វើពិធីសែនព្រេន និងទទួលបានការប្រោះព្រំពីអ្នកតាចាស់ស្រុក (យាយរដ្ឋ) រួចមក ជម្មើងទី១ (អ្នករៀបចំកិច្ច) បានយកពូជស្រូវមកព្រោះនៅលើក្រមានិងមួក ក្នុងបំណងថា សូមឲ្យការធ្វើស្រែចំការ ឬការដាំដុះស្រូវដំណាំនាដូវថ្មីនេះ កើតការបែកគុម្ពល្អ និងមានទឹកភ្លៀងពេញបរិបូណ៌។ ពេលជម្មើងទី១បាចរួច ជម្មើងសួរថាតើការព្រោះនេះស្មើភាពគ្នានិងសព្វគ្រប់គ្នាហើយឬនៅ? មានធកមានល្វែងឬអត់? បើអ្នកចូលរួមឆ្លើយថា "នៅទេ" នោះនឹងមានជម្មើងទី២ និងទី៣ មកព្រោះម្តងទៀត រហូតដល់អ្នកចូលរួម

អត្ថបទដោយៈ ម៉ង់ វ៉ាលី

ឆ្លើយថា "សព្វគ្រប់ហើយ" ទើបចាស់ស្រុកឱ្យអ្នកចូលរួមប្រមូលពូជស្រូវនោះ។ ការប្រមូលទៀតសោត គេត្រូវយកពូជស្រូវពាក់កណ្ដាលបរិច្ចាកជូនវត្ត (បរិច្ចាកជូនអ្នកតាចាស់ស្រុក) ហើយពាក់កណ្ដាលទៀតយកទៅដាក់នៅក្នុងច្រមនាសសរកន្ទោងតាមផ្ទះរៀងខ្លួន ដែលគេហៅថា "មេស្រូវ" ដើម្បីការពារកុំឱ្យពូជស្រូវមានភាពភិតភ័យនៅពេលគេចាប់ផ្ដើមយកពូជស្រូវទៅបង្កបង្កើនផលឱ្យកើតការបែកគុម្ពល្អ មានទឹកភ្លៀងពេញបរិបូណ៌។

ជារួមមក កិច្ចច្រត់ព្រះនង្គ័លនៅតំបន់សំបូរព្រៃគុក បានបង្ហាញឱ្យឃើញពីការរក្សាមត៌កអរូបិយមួយដ៏ពិសេស ដែលស្ទើរតែមិនមាននៅតំបន់ដទៃទៀតនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ លំដាប់លំដោយនៃកិច្ចច្រត់ព្រះនង្គ័លនៅក្នុងភូមិទាំងពីរ (ភូមិសំបូរ និងភូមិចំណារចាស់) ដែលបានរៀបរាប់ខាងលើ មិនមានលក្ខណៈដូចព្រះរាជពិធីច្រត់ព្រះនង្គ័លដែលរៀបចំឡើងដោយថ្នាក់ជាតិនោះទេ ប៉ុន្តែអត្ថន័យរួម ហាក់ដូចជាពុំខុសគ្នាឡើយ គឺការបើករដូវធ្វើស្រែ និងសូមឱ្យមានទឹកភ្លៀងពេញបរិបូណ៌។

## បញ្ជីឯកសារពិគ្រោះ


ចាប ពិន ១៩៦០, *ព្រះរាជពិធីទ្វាទសមាស*, ភាគ ៣, ពុទ្ធសាសនបណ្ឌិត្យ, ភ្នំពេញ។

មាស សុភាព ២០២១, 'ព្រះរាជពិធីច្រត់ព្រះនង្គ័ល', អត្ថបទផ្សាយក្នុងគេហទំព័រ AMS អរិយធម៌ខ្មែរ, (ផ្សាយអនឡាញ)។

សាន់ ស៊ីថុន ២០០៨, "ច្រត់ព្រះនង្គ័ល", អត្ថបទផ្សាយក្នុងគេហទំព័រ បណ្ដាញពត៌មានវប្បធម៌ខ្មែរ, តាមរយៈតំណភ្ជាប់ https://www.yosothor.org/publications/khmer-renaissance/chapter-two/chrot-phreas-neang-kol.html

ហួន សារ៉ង ២០២២, 'ទិដ្ឋភាពព្រះរាជពិធីច្រត់ព្រះនង្គ័លក្នុងសង្គមខ្មែរ', អត្ថបទផ្សាយក្នុងគេហទំព័រ AMS អរិយធម៌ខ្មែរ, (ផ្សាយអនឡាញ)។

Armstrong, E. A. 1943. 'The Ritual of the Plough'. Folklore 54, no. 1: 250–57.


អត្ថបទដោយ៖ ម៉ង់ រ៉ាលី





រូបលេខ១ ទិដ្ឋភាពរួមប្រុត់ព្រះនង្គ័លភូមិសំបូរ    រូបលេខ២ ព្រលឹងស្រូវក្នុងកិច្ចប្រុត់ព្រះនង្គ័លភូមិសំបូរ





រូបលេខ៣ ដើមព្រះភូមិ ប្រុត់ព្រះនង្គ័លភូមិសំបូរ    រូបលេខ៤ កិច្ចសែនព្រេន ប្រុត់ព្រះនង្គ័លភូមិសំបូរ





រូបលេខ៥-៦៖ កិច្ចបញ្ជូន ប្រុត់ព្រះនង្គ័លភូមិសំបូរ

អត្ថបទដោយ៖ ម៉ង់ វ៉ាលី





រូបលេខ៧-៨ៈ  យកដើមព្រះភូមិទៅដោតនៅដីស្រែ ច្រត់ព្រះនង្គ័លភូមិសំបូរ





រូបលេខ៩-១០ៈ  កិច្ចដុសរំអិលថ្មនៅខាងមុខខ្ទមអ្នកតាចាស់ស្រុកជណ្ដើរបុរាណក្រុមប្រាសាទសំបូរ
ច្រត់ព្រះនង្គ័លភូមិសំបូរ





រូបលេខ១១-១២ៈ អ្នកស្រុករង់ចាំទទួលរំអិលថ្ម ច្រត់ព្រះនង្គ័លភូមិសំបូរ

អត្ថបទដោយៈ ម៉ង់ វ៉ាលី





រូបលេខ១៣-១៤ ជម្នឿងឆ្លើយឆ្លងជាមួយបុរសរំអិលថ្ម ការចឹមទៅលើថ្ងាសក្មេងៗ ប្រត់ព្រះនង្គ័លភូមិសំបូរ





រូបលេខ១៥-១៦ ក្មេងៗដែលទទួលបានរំអិលថ្មចឹមទៅលើថ្ងាស ប្រត់ព្រះនង្គ័លភូមិសំបូរ

អរិយធម៌ខ្មែរ
KHMER CIVILIZATION

អត្ថបទដោយ៖ ម៉ង់ វ៉ាលី



រូបលេខ១៧ គ្រាប់ពូជស្រូវដែលយកមកពីផ្ទះ ចាក់ចូលចានធំមួយរួមគ្នា ច្រត់ព្រះនង្គ័លភូមិចំណារចាស់
(រូបថត៖ អាន រស្មី)



រូបលេខ១៨ អ្នកចូលរួមពិធីនាំគ្នាក្រាលក្រមានិងមួក ច្រត់ព្រះនង្គ័លភូមិចំណារចាស់
(រូបថត៖ អាន រស្មី)

អត្ថបទដោយ៖ ម៉ង់ វ៉ាលី



រូបលេខ១៩ អ្នកតាចាស់ស្រុកឱ្យពរជ័យ ច្រត់ព្រះនង្គ័លភូមិចំណារចាស់
(រូបថត៖ អាន រស្មី)



រូបលេខ២០ ជម្មឿងបាចគ្រាប់ពូជស្រូវដែលបានទទួលពរពីអ្នកតា ច្រត់ព្រះនង្គ័លភូមិចំណារចាស់
(រូបថត៖ អាន រស្មី)

អត្ថបទដោយ៖ ម៉ង់ វ៉ាលី



រូបលេខ២១ អ្នកចូលរួមប្រមូលគ្រាប់ពូជស្រូវដែលបានទទួលពរពីអ្នកតា ច្រត់ព្រះនង្គ័លភូមិចំណារចាស់ (រូបថត៖ អាន រស្មី)



រូបលេខ២២ អ្នកចូលរួមប្រមូលគ្រាប់ពូជស្រូវដែលបានទទួលពរពីអ្នកតា ច្រត់ព្រះនង្គ័លភូមិចំណារចាស់ (រូបថត៖ អាន រស្មី)

អត្ថបទដោយ៖ ម៉ង់ វ៉ាលី